គម្រោងអង្គាសសង្ខេប

# អំណានយុវជន

## I. សារពីក្រុមការងារអង្គាស

ខ្ញុំឈ្មោះ (ឡាំ ឡាយ, ណន យ៉ា, លី សុតី, ទេព សុផានេត,ប៉ៅ វិសាល, អ៊ីត រចន្នី) គឺជាក្រុមការងារស្ម័គ្រចិត្តផ្នែកអង្គាសជាមួយ **“អំណានយុវជន”** ឬភាសាអង់គ្លេស **“AmnanYuveaJun”** ដែលហៅកាត់ថា (AYN)។ ក្រុមនេះដំណើរការដោយយុវជនមួយក្រុម ដែលស្រឡាញ់ចូលចិត្តការអានសៀវភៅ និង ត្រូវបានបង្កើតឡើងក្នុងគោលបំណងមិនដើម្បីស្វែងរកប្រាក់ចំណេញនោះទេ។ បច្ចុប្បន្ននេះក្រុមការងារអំណាន បាននឹងកំពុងធ្វើការដើម្បីពង្រឹងសក្តានុពលនៃវប្បធម៌អំណានក្នុងប្រទេសកម្ពុជា។

ហេតុអ្វីបានជាត្រូវជំរុញវប្បធម៌អំណាន? បញ្ហាចំចម្បងមួយចំនួនជាក់ស្តែង គឺយុវជនយើងសព្វថ្ងៃហាក់ដូចជាពុំសូវឈ្វេងយល់ឱ្យស៊ីជម្រៅទៅលើការអាន ឬហាក់ពុំយល់ដឹងអំពីអត្ថប្រយោជន៍នៃអំណាន និងបើមានដែរ គឺមានចំនួនតិចតួចស្តួចស្តើងណាស់។ ដោយសារតែកង្វះខាត ការពង្រឹងទម្លាប់នៃអំណាន ស្របពេលដែល ទម្លាប់របស់ពួកគេរាល់ថ្ងៃ ត្រូវបានគ្របដណ្តប់ដោយភាពជឿនលឿននៃបច្ចេកវិទ្យា (បច្ចេកវិទ្យាជឿនលឿនស្របពេលដែលយុវជនគ្មានវិន័យច្បាស់លាស់)។ យុវជនភាគច្រើនខ្ជះខ្ជាយពេលវេលា និងធនធានយ៉ាងច្រើន ព្រោះតែឥទ្ធិពលនៃប្រព័ន្ធផ្សព្វផ្សាយសង្គម និង ការញៀនទៅនឹងបច្ចេកវិទ្យាខុសគោលដៅ។ យើងទទួលស្គាល់ថាបច្ចេកវិទ្យាជឿនលឿន គឺជាផ្នែកមួយនៃការជំរុញភាពរីកចម្រើនក្នុងសង្គម។ ក៏ប៉ុន្តែប្រសិនជាយុវជនយើងខ្វះសមត្ថភាពរៀបចំវិន័យខ្លួនឯង សួរថាតើបច្ចេកវិទ្យានឹងនាំខ្លួនយុវជនប្រភេទនោះទៅដល់គម្លាតណា? ភាពខ្លាំងរបស់សង្គមមួយ ពុំមែនត្រូវការយុវជនដែលខ្វះវិន័យផ្ទាល់ខ្លួនទេ តែជាវិន័យប្រកបដោយការទទួលខុសត្រូវ។ តើដើម្បីដោះស្រាយបញ្ហាទាំងអស់នោះ យើងត្រូវចាប់ផ្តើមពីជំហានណា?

គោលបំណងរបស់ “អំណានយុវជន” គឺផ្តល់ឱ្យនូវធនធាន និង ការតម្រង់ទិស ដែលអាចឱ្យយុវជនទទួលបានការអប់រំប្រសើរជាងមុន ទៅលើការអាន ការនិយាយ ការសរសេរ ការគិត និង ផ្ទត់គំនិតនៃភាពជាអ្នកដឹកនាំតាមបែបស៊ីជម្រៅទៅកាន់យុវជនកម្ពុជាពីមួយជំហានទៅមួយជំហាន។ អ្វីដែលក្រុមការងារយើងចង់ឃើញ គឺជាភាពប្រសើរឡើងនៃការអភិវឌ្ឍខ្លួនដោយពឹងផ្អែកទៅលើការអប់រំ និងអំណានតែម្តង។ ចង់ឱ្យប្រទេសរឹងមាំ ចង់មិនចង់ត្រូវពឹងលើវិស័យសិក្សាធិការជាស្នូល។

*ដើម្បីឱ្យគោលបំណងនេះអាចសម្រេចទៅបាន ក្រុមការងារអំណានយុវជន កំពុងរៀបចំគម្រោងប្រមូលមូលនិធិដើម្បីទ្រទ្រង់ក្នុងដំណើរប្រតិបត្តិការឱ្យមាននិរន្តរភាព។ យើងខ្ញុំមានកិត្តិយស ចែករំលែកដល់លោក លោកស្រី ដែលមាននិស្ស័យទស្សនវិស័យដូចគ្នា និង ជឿជាក់លើចលនាពង្រីកសក្តានុពលវប្បធម៌អំណាន ដើម្បីចូលរួមឧបត្ថម្ភគាំទ្រដល់បេសកកម្មរបស់យើងខ្ញុំឱ្យមានប្រសិទ្ធិភាពយូរអង្វែង។ លោក លោកស្រី គឺជាផ្នែកមួយដ៏សំខាន់បំផុតនៃចលនានេះ ដើម្បីជំរុញវប្បធម៌អំណាននៅកម្ពុជាឱ្យរស់រវើកឡើងវិញ ដែលជាអត្ថប្រយោជន៍ដល់យុវជនជំនាន់នេះនិងអ្នកជំនាន់ក្រោយ។ ក្តីសង្ឃឹមរបស់អំណានយុវជន គឺពឹងលើការចូលរួមរបស់អ្នកទាំងអស់គ្នា។ ប្រសិនបើលោក លោកស្រីមានសំណួរ យើងខ្ញុំរីករាយនឹងឆ្លើយតបតាមលទ្ធភាពអំពីព័ត៌មានទាំងឡាយនៃកម្មវិធីមួយនេះ តាមប្រព័ន្ធទាក់ទងខាងក្រោម។*

*អ៊ីមែល៖ fundraiseamnanyuveajun@gmail.com ឬទូរស័ព្ទលេខ ០៦៩ ២២៣ ៥៥៩ / ០៧៧ ២៥ ១៩ ១៣ឬចូល*
*មើលទំព័រហ្វេសប៊ុករបស់យើង:* www.facebook.com/AmnaanYuveajun

## II. ប្រវត្តិរបស់អំណានយុវជន

**"អំណានយុវជន"** ត្រូវបានបង្កើតឡើងនៅអំឡុងដើមឆ្នាំ ២០១៧ ដោយសហស្ថាបនិក ៣រូប គឺរួមមានលោក ឡាំ លីម លោក ឡាំ ឡាយ និង លោក ទេព សុផានេត ។ លោកទាំង៣រូប បានចូលរួមទាំងចំណេះដឹង ពេលវេលា និង ធនធានមួយចំនួនទៀតដើម្បីរៀបចំចងក្រងឡើងជាឯកសារ វេទិកា និង សកម្មភាពនានា ដែលពាក់ព័ន្ធនឹងយុវជនមួយចំនួនក្នុងតំបន់។ បន្ទាប់ពីសាកល្បងសកម្មភាពនេះដោយជោគជ័យ ក្រុមការងារនេះចាប់ផ្ដើមទទួលបានការឆ្លើយតបជាវិជ្ជមានពីសំណាក់អ្នកចូលរួម យុវជនគ្រប់ច្រកល្ហក និងតាមបណ្ដាស្ថាប័ននានាផងដែរ។ ពួកគាត់បានប្រាប់ដោយតាសានៃក្ដីយល់ចិត្តថា ***"អំណានយុវជន ពិតជាបានកសាងគ្រឹះយុវជនកម្ពុជាតាមរយៈការអាន និងពិតជាធ្វើដំណើរដោយស្នាមញញឹមប្រកបដោយស្មារតីទទួលខុសត្រូវ"*** ។ គួរបញ្ជាក់ផងដែរថា បច្ចុប្បន្ននេះ សហស្ថាបនិកទាំងបីរូបបានបែងចែកកិច្ចការងារដាច់ដោយឡែកពីគ្នា ដោយ លោក ឡាំ លីម គឺជាប្រធានក្រុមប្រឹក្សាភិបាល។ លោក ឡាំ ឡាយ ជាអ្នកដឹកនាំទូទៅ និងបណ្ដុះបណ្ដាលយុវជន ដើម្បីដឹកនាំកម្មវិធីអំណានបន្ត។ ហើយនិងលោក ទេព សុផានេត ជាក្រុមប្រឹក្សាភិបាល និងជាអ្នកកៀកគរ ធនធាន មូលនិធិនានា ដើម្បីធ្វើឱ្យអំណានយុវជនបន្តដំណើរទៅមុខទៀត។

បច្ចុប្បន្ននេះ **អំណានយុវជន** បាននិងកំពុងចាប់ផ្ដើមចូលរួមជាមួយសកម្មភាពផ្សេងៗទៀត និង បានខិតខំបង្កើតព្រឹត្តិការណ៍ផ្សេងៗ ដើម្បីឆ្លើយតបទៅនឹងបញ្ហាអំណានដែលយុវជនកម្ពុជាកំពុងតែជួបប្រទះ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ "អំណានយុវជន" បានបន្តពង្រីកកម្មវិធីផ្សេងៗ និង ក្រុមការងារចំណានៗជាច្រើននាក់ ដើម្បីយកចិត្តទុកដាក់លើទិដ្ឋភាពផ្សេងៗនៃបេសកម្មមួយនេះឱ្យបានសម្រេចពីមួយជំហាន ទៅមួយជំហាន។ ហើយរឿងដែលប្រសើរបំផុត "ក្រុមការងារអំណានយុវជន" បានពង្រីកសក្ដានុពលខ្លួន រហូតអាចបង្កើតក្រុមការងារស្នូលនៅលើទឹកដីបាត់ដំបង ហើយនឹងការត្រៀមខ្លួនរួចរាល់ដើម្បីរៀបចំក្រុមការងារមួយក្រុមទៀតគឺនៅខេត្ត "បន្ទាយមានជ័យ"។ ជារួមក្រុមការងារស្នូលរបស់ "អំណានយុវជន" បូកសរុបទាំងខេត្តសៀមរាបនិងបាត់ដំបងគឺចំនួន ២៦រូបស្រីចំនួន១៦រូប និងព្រះសង្ឃ៨អង្គ។

## III. ឧត្តមវិស័យ និង បេសកកម្ម

### ១. ឧត្តមវិស័យ

ជំរុញយុវជន ពីអ្នកអានធម្មតា ទៅជាអ្នកអានប្រកបដោយការត្រិះរិះពិចារណាបែបស៊ីជម្រៅ ពីអ្នកអានដែលមានការពិចារណាបែបស៊ីជម្រៅទៅជាអ្នកដឹកនាំដ៏មានសក្ដានុពលម្នាក់នាពេលអនាគត។

### ២. បេសកកម្ម

អំណានយុវជន ជំរុញសកម្មភាពអំណាននៅជុំវិញរាជធានីខេត្តទៅកាន់យុវជនកម្ពុជាតាមរយៈការ៖

- ផ្ដល់ជូនវេទិកាបណ្ដុះបណ្ដាលសមត្ថភាពរយៈពេល១២សប្ដាហ៍
- ផ្ដល់ជាសារសំឡេង ឬសំឡេងអំណានទៅកាន់យុវជនកម្ពុជា
- ផ្ដល់ជាវេទិកាជំនួបអ្នកអាន និងអ្នកនិពន្ធ ចំនួន៩ខេត្តក្នុង១ឆ្នាំ
- ផ្ដល់ជូនការស្រាវជ្រាវ និងការបណ្ដុះបណ្ដាលក្នុងវិស័យអំណាន

- រៀបចំជាវេទិការវាងអ្នកនិពន្ធ និងអ្នកអានដើម្បីផ្សព្វផ្សាយស្នាដៃថ្មីៗ

### ៣. គុណតម្លៃ

ក្នុងការបំពេញបេសកកម្ម និងយោងតាមទស្សនវិស័យរបស់អំណានយុវជន ក្រុមការងារនឹងបោះជំហានទៅមុខដោយគុណតម្លៃចំនួន៥ ដូចជា៖

- ព្រលឹងនៃសាមគ្គីភាព
- សុចរិតភាព និងតម្លាភាព
- ក្ដីសង្ឃឹម និងភាពជាអ្នកដឹកនាំក្នុងខ្លួនឯង
- ការគោរព និងផ្ដល់តម្លៃគ្នាទៅវិញទៅមក
- គុណភាព និងវិជ្ជាជីវៈ

## IV. គម្រោង និង កម្មវិធី

បច្ចុប្បន្ននេះ យើងមានក្រុមការងារសកម្មជាច្រើននាក់ បាននិងកំពុងឆ្លៀតពេលវេលាពីការងារស្នូលរបស់ពួកគាត់មកជួយធ្វើការលើកម្មវិធីផ្សេងៗរបស់ “អំណានយុវជន”។ ហើយពួកយើងធ្វើការយ៉ាងជិតស្និទ្ធ និង មានប្រសិទ្ធភាព ជាមួយដៃគូរសហការនៃអង្គភាពមួយចំនួន ក៏ដូចជាយុវជននៅក្នុងតំបន់។ អំណានយុវជន បានបង្កើតកម្មវិធី និងគម្រោងមួយចំនួនដូចខាងក្រោម៖




### ១. កម្មវិធីបណ្ដុះបណ្ដាលសមត្ថភាពអំណានរយៈពេល១២សប្ដាហ៍

បច្ចុប្បន្នកម្មវិធីនេះ កំពុងដំណើរការយ៉ាងសកម្មនៅក្នុងខេត្តសៀមរាប ដោយមានកិច្ចសហការជាមួយ **សាកលវិទ្យាល័យបៀលប្រាយខេត្តសៀមរាប** ដែលយើងបានបណ្ដុះបណ្ដាលយុវជនអំណានបានចំនួន ៥ ជំនាន់រួចមកហើយ ។ (សូមអានត្រង់មាតិកា “សមិទ្ធផល និងរបាយការណ៍សង្ខេប” ខាងក្រោមបន្ថែម)

## ២. ព្រឹត្តិការណ៍ជំនួបអ្នកអាន ៩ ខេត្ត/ក្រុង

ព្រឹត្តិការណ៍នេះ នឹងធ្វើដំណើរ ៩ ខេត្ត/ក្រុង នៃប្រទេសកម្ពុជាក្នុងរយៈពេល១ឆ្នាំ ដើម្បីឱ្យអ្នកអាន និងអ្នកនិពន្ធ យុវនិពន្ធ មានឱកាសក្នុងការចែករំលែកអំពីការអាន ការសរសេរ បទពិសោធ និងចំណេះដឹងនានាពាក់ព័ន្ធនឹងសង្គម។ រហូតមកដល់ពេលនេះ យើងបានរៀបចំព្រឹត្តិការណ៍ចំនួន ៣ នៅក្នុងខេត្តសៀមរាប បាត់ដំបង និង ភ្នំពេញ និងព្រឹត្តិការណ៍មួយទៀតដែលគ្រោង នឹងធ្វើនៅខេត្តកោះកុងនៅពេលដែលស្ថានភាពរីករាលដាល មេរោគកូវីដ-១៩ ត្រូវបានបញ្ចប់។ ព្រឹត្តិការណ៍ ៥ ទៀតនឹងត្រូវរៀបចំឡើងនៅខេត្តបន្ទាយមានជ័យ កំពង់ឆ្នាំង ស្វាយរៀង ពោធិ៍សាត់ និង កំពត។

## ៣. ព្រឹត្តិការណ៍សម្ពោធសៀវភៅ

ព្រឹត្តិការណ៍នេះ មានគោលបំណងណែនាំសៀវភៅថ្មី ឬ អ្នកនិពន្ធថ្មីដល់សាធារណជន។ យើងធ្វើនេះ ដើម្បីធ្វើបែបណា ដើម្បីឱ្យអ្នកអានបានជជែកសួរនាំអំពី បុព្វហេតុនៃការសរសេរ និពន្ធ ឬក៏ការចងក្រងសៀវភៅមួយនោះឡើង។ អាចនិយាយដោយសង្ខេបថា "ដើម្បីឱ្យអ្នកនិពន្ធ បានចែករំលែកអំពីស្នាដៃខ្លួន និងអ្នកអានអាចសាកសួរអំពីស្នាដៃមួយនោះ"។ កន្លងទៅ ក្រុមការងារ បានជោគជ័យទៅលើព្រឹត្តិការណ៍២ធំៗគឺ ព្រឹត្តិការណ៍ សម្ពោធសៀវភៅដំណើរ និងសៀវភៅស្តេចនំដូណាត់។ ក្រុមការងារ ក៏មានគម្រោងរៀបចំជាវេទិកាបន្តបន្ទាប់ទៀតដែរ។

## ៤. កម្មវិធីកិច្ចសន្ទនាអំណានយុវជន (Podcast, Video & Audio)

កម្មវិធីនេះមានគោលបំណងបង្កើតវេទិកាមួយ ដើម្បីពិភាក្សាតាមបែបឌីជីថល (Digital) នៅក្នុងប្រធានបទជុំវិញនឹងអំណាននៅកម្ពុជា។ ជាមួយគ្នានេះដែរ ក្រុមការងារកំពុងធ្វើការរៀបចំសម្រួលអត្ថបទក្នុងសៀវភៅទៅជាសារសំឡេង ក៏ដូចជាវីដេអូដើម្បីឱ្យអត្ថបទអប់រំទាំងនេះអាចសម្រួលទៅដល់ទស្សនិកជនបានកាន់តែច្រើន ជាពិសេសនៅក្នុងស្ថានភាពនៃការរក្សាគម្លាតសង្គមនេះ។ អំណានយុវជន ក៏កំពុងតែរៀងអង្គាសដើម្បីបង្កើតគេហទំព័រ (Website) ដើម្បីបង្កភាពងាយស្រួលក្នុងការរុញច្រានចំណេះដឹងអំណាននេះ ឆាប់ដល់ដៃយុវជន និងអ្នកនិយមអំណានផងដែរ។

## ៥. មជ្ឈមណ្ឌលអាន និង ស្រាវជ្រាវ

មជ្ឈមណ្ឌលនេះ ត្រូវបានបង្កើតឡើងដោយមានការឧបត្ថម្ភគាំទ្រពីសប្បុរសជននានា ដើម្បីបង្កើតជាកន្លែងដែលអ្នកស្ម័គ្រចិត្ត និង ក្រុមការងារអំណានយុវជន អាចប្រើជាការិយាល័យដើម្បីធ្វើការលើកម្មវិធីផ្សេងៗរបស់អំណានយុវជន ក៏ដូចជាកសាងជាកន្លែងសម្រាប់ការអាន ការសរសេរ និង ការស្រាវជ្រាវ សម្រាប់អ្នកដែលមានបំណងចង់បង្កើនជំនាញស្រាវជ្រាវរបស់ពួកគាត់។ ទីតាំងគឺនៅក្នុង សាខាសាកលវិទ្យាល័យខេត្តសៀមរាបតែម្តង។

## ៦. ក្រុមការងារ អំណានយុវជនបាត់ដំបង

គឺជាកម្មវិធី បណ្តុះបណ្តាលអំណានរយៈពេល១២សប្តាហ៍ និងជាក្រុមការងារមួយដែលនឹងអាចក្លាយជាក្រុមស្នូលសម្រាប់ដឹកនាំគម្រោងនានានៅខេត្តបាត់ដំបងនេះតែម្តង។ សកម្មភាពមួយចំនួន យើងមានការជ្រោមជ្រែងយ៉ាងពេញទំហឹង ពីសំណាក់យុវជន និងជាពិសេស គឺសមាគមហ្សារពន្លឺសិល្បៈនៅខេត្តបាត់ដំបង។

**៧. ក្រុមការងារ អំណានយុវជនខេត្តបន្ទាយមានជ័យ**

កំពុងតែដំណើការរៀបចំ។ ពន្យាពេលព្រោះតែវិបត្តិនៃជំងឺកូវីដ-១៩។

# V. សមិទ្ធផល និងរបាយការណ៍សង្ខេប

## ១. កម្មវិធីបណ្តុះបណ្តាលយុវជនអំណាន១២សប្តាហ៍

- **ជំនាន់ទី១** សមាជិកបានបញ្ចប់វគ្គបណ្តុះបណ្តាល៣ខែដោយជោគជ័យមាន ១៣នាក់ មានស្រី ៨ នាក់ ព្រះសង្ឃ១អង្គ  ( ៨១២នាក់) ហើយចំណាយថវិកាចំនួន ១១២២ ដុល្លារ
- **ជំនាន់ទី២** សមាជិកបានបញ្ចប់វគ្គបណ្តុះបណ្តាល៣ខែដោយជោគជ័យមាន ១២នាក់ មានស្រី ៦ នាក់ ព្រះសង្ឃ២អង្គ  ( ៩០៨នាក់) ហើយថវិកាចំនួន ១០២១ ដុល្លារ
- **ជំនាន់ទី៣** សមាជិកបានបញ្ចប់វគ្គបណ្តុះបណ្តាល៣ខែដោយជោគជ័យមាន ១៣នាក់ មានស្រី ៦ នាក់ ព្រះសង្ឃ២អង្គ  ( ១០០២នាក់) ហើយចំណាយថវិកាចំនួន ១០០១ ដុល្លារ
- **ជំនាន់ទី៤** សមាជិកបានបញ្ចប់វគ្គបណ្តុះបណ្តាល៣ខែដោយជោគជ័យមាន ១២នាក់ មានស្រី ៥ នាក់ ព្រះសង្ឃ២អង្គ  ( ៩១២នាក់) ហើយចំណាយថវិកាចំនួន ១១២២ ដុល្លារ

សរុប គម្រោងនេះ យើងបានផ្សព្វផ្សាយតាមរយៈការផ្សាយផ្ទាល់ដោយមានអ្នកដែលបានឃើញនៅលើបណ្តាញសង្គមចំនួនប្រមាណជា ៣ម៉ឺននាក់

ថវិកាគឺយើងទទួលបានពីសប្បុរសជន និងសាកលវិទ្យាល័យបៀលប្រាយសៀមរាប

**ចំណាយសរុបអស់ ៤២៨៨ ដុល្លា អ្នកចូលរួមដោយផ្ទាល់ចំនួន ៣៦៣០នាក់ ក្នុងនោះមានស្រី ៦០ ភាគរយ**

## ២. កម្មវិធីជំនួបអ្នកអាន

- **គម្រោងទី២ វេទិកាជំនួបអ្នកអាន ៩ ខេត្តក្រុង** (៤០០២ដុល្លា)
  - ខេត្តសៀមរាប មានចំនួន ៧៥ នាក់នៅ Footprint café
  - ខេត្តបាត់ដំបង មានចំនួន ១៧៨ នាក់នៅ BBU បាត់ដំបង
  - រាជធានីភ្នំពេញ មានចំនួន ២១៨ នាក់នៅ BBU ភ្នំពេញ
  - *កុះកុង (បានផ្សព្វផ្សាយរួចរាល់ហើយ ប៉ុន្តែពន្យាពេលព្រោះតែជំងឺរាតត្បាតកូវីដ-១៩)*
  - បន្ទាយមានជ័យ (កំពុងដំណើរការ)
  - ស្វាយរៀង (កំពុងដំណើរការ)
  - កំពង់ឆ្នាំង (កំពុងដំណើរការ)
  - កំពត (កំពុងដំណើរការ)
  - ពោធិ៍សាត់ (កំពុងដំណើរការ)

តាមគម្រោងការណ៍យើងនឹងទៅជួបអ្នកអានដោយផ្ទាល់ ចំនួន ១០៩៥នាក់

### ៣. កម្មវិធី មជ្ឈមណ្ឌលស្រាវជ្រាវ និងបណ្តុះបណ្តាល

ជាការិយាល័យរបស់អំណានយុវជនដែលមានទីតាំងស្ថិតនៅក្នុងអគារនៃសាខាសាកលវិទ្យាល័យបៀល ប្រាយខេត្តសៀមរាប។ ការិយាល័យរបស់អំណានយុវជននេះបង្កើតឡើងក្នុងគោលបំណងបីយ៉ាងសំខាន់ៗ៖ ទី១ ជាទីកន្លែងសម្រាប់ប្រតិបត្តិការគម្រោងអំណានសាកលវិទ្យាល័យខេត្តសៀមរាប។ ទី២ ជាទិសដៅសម្រាប់បង្កើតធនធានបន្តវេនរបស់អំណានយុវជន រួមមានការបណ្តុះបណ្តាល ការអនុវត្តជាមួយនឹងគម្រោងផ្ទាល់ និងចុងក្រោយជាទីកន្លែងសម្រាប់ស្រាវជ្រាវ របស់ស្នេហវ័យក្មេង ឬយុវនិពន្ធវ័យក្មេង។ ថវិការដែលចំណាយទៅលើសម្ភារ ឬគ្រឿងបរិក្ខារនានា គឺក្រុមការងារអំណានយុវជន បានចំណាយពេលវេលារយៈពេលប្រមាណជា១ខែ ក្នុងការរៃអង្គាសបានថវិកាប្រមាណ ១៥០០ដុល្លារសហរដ្ឋអាមេរិក។

### ៤. កម្មវិធី សម្ពោធសៀវភៅ

- សម្ពោធសៀវភៅ អំណានជាអំណាច ដែលមានអ្នកចូលរួមចំនួន ២១៣នាក់
- សម្ពោធសៀវភៅ ដំណើរ នៅសាកលវិទ្យាល័យ ផារ៉ាហ្គនអន្តរជាតិ ដែលមានអ្នកចូលរួមចំនួន ២០០នាក់
- សម្ពោធសៀវភៅ ស្តេចនំដូណាត់ (Donut king) ដែលមានអ្នកចូលរួមចំនួន ១៥០នាក់ នៅ ផារ៉ាហ្គនអន្តរជាតិ

### ៥. ក្រុមការងារ អំណានយុវជនបាត់ដំបង

- **ជំនាន់ទី១** សមាជិកបានបញ្ចប់វគ្គបណ្តុះបណ្តាល៣ខែដោយជោគជ័យមាន ២០នាក់ ស្រី១២នាក់ ព្រះសង្ឃ២អង្គ ( ៨១២នាក់) ហើយចំណាយអស់ថវិកាចំនួន ១០២២ ដុល្លារ។

### ៦. ក្រុមការងារ អំណានយុវជនខេត្តបន្ទាយមានជ័យ

- **ជំនាន់ទី១** នឹងដំណើរការនាពេលឆាប់ៗខាងមុខនេះ។

## VI. កម្មវត្ថុនៃគម្រោងការ

ដោយសារចង់ឱ្យសកម្មភាពនៃកម្មវិធីរបស់អំណានយុវជននៅតែបន្ត ពួកយើងគ្រប់គ្នាបានលះបង់ពេលវេលា កម្លាំងកាយចិត្ត និង ធនធានផ្សេងៗ ក្រៅពីអាជីពស្នូលរបស់យើង ដើម្បីធានាឱ្យបានថាសកម្មភាពទាំងនេះនៅតែត្រូវបានប្រតិបត្តិ និង អភិវឌ្ឍបានយ៉ាងល្អប្រសើរជាយូរអង្វែងទៅមុខទៀត។

គួរបញ្ជាក់ផងដែរថា ពួកយើងបាននឹងកំពុងធ្វើការលើវេទិកាផ្សេងៗជាច្រើនទៀត តាមរយៈការផលិតជាវីដេអូ រូបភាព សំឡេង ឬទម្រង់នៃការសរសេរ ដើម្បីធ្វើឱ្យប្រាកដថា សារទាំងឡាយពីអំណានយុវជនត្រូវបានបញ្ជូនទៅប្រកបដោយប្រសិទ្ធភាព ដល់យុវជនទាំងឡាយ ជាពិសេសសម្រាប់អ្នកដែលត្រូវការវាជាចាំបាច់។ ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ ជាសំណាងល្អ ដោយមានអង្គការ និង សប្បុរសជនមួយចំនួន ដែលបានជឿទុកចិត្តយ៉ាងមុតមាំ និង គាំទ្រផ្នែកខ្លះនៃសកម្មភាពរបស់យើង ដែលអាចឱ្យយើងបន្តសកម្មភាពរហូតមកដល់ពេលនេះ។

## VII. ការធ្វើសមាហរណកម្មមូលនិធិ

គោលបំណងនៃការធ្វើសំណើរនេះ គឺដើម្បីរៃអង្គាសថវិកា**ចំនួន ៤,៩៥០** ដុល្លារ សហរដ្ឋអាមេរិក (USD) សម្រាប់ប្រតិបត្តិការប្រចាំឆ្នាំរបស់ អំណានយុវជន (ឧសភា ២០២១ - ឧសភា ២០២២)។

| លេខ | គម្រោង | ការចំណាយ | រយៈកាល | ការកត់ត្រា |
|---|---|---|---|---|
| 1 | កម្មវិធីជំនួបអ្នកអាន៩ខេត្ត | 1500$ | 2021-2022 | |
| 2 | អំណាន BBU | 500$ | 2021-2022 | |
| 3 | កម្មវិធីអំណានយុវជនបាត់ដំបង | 700$ | 2021-2022 | |
| 4 | គម្រោងសារសំឡេង | 600$ | 2021-2022 | |
| 5 | កម្មវិធីអំណានយុវជនបន្ទាយមានជ័យ | 1000$ | 2021-2022 | |
| 6 | ចំណាយប្រតិបត្តិការការិយាល័យ | 400$ | 2021-2022 | AYN Office |
| 7 | ចំណាយផ្សេងៗ | 250$ | 2021-2022 | Emergency |
| | Total | 4950$ | | |

សូមបញ្ជាក់ផងដែរ មូលនិធិនេះនឹងត្រូវបានប្រើប្រាស់សម្រាប់តែ បេសកកម្មរបស់អំណានយុវជនក្នុងគោលបំណងនៃការប្រតិបត្តិ និង អភិវឌ្ឍវប្បធម៌អំណាននៅកម្ពុជាតែប៉ុណ្ណោះ។ ការរៀបចំកម្មវិធីមូលនិធិរៃអង្គាសនេះឡើង ក្នុងគោលបំណងចង់ឱ្យក្រុមការងារ “អំណានយុវជន” អាចអនុវត្តសកម្មភាពរបស់ខ្លួនមានប្រសិទ្ធភាព និង និរន្តរភាព។ អ្នកទាំងអស់គ្នា គឺជាចំណែក និងក្តីសង្ឃឹមរបស់យុវជនជំនាន់ក្រោយ៕

**ដោយក្តីគោរពរាប់អាន ពីក្រុមការងារអំណានយុវជន**



**លោក ឡាំ ឡាយ**


សហស្ថាបនិក និងអ្នកដឹកនាំ

Emaill: fundraiseamnanyuveajun@gmail.com


SCAN US TO OUR FACEBOOK PAGE

ឧបសម្ព័ន្ធ៖

ទម្រង់យោង៖

១- គម្រោងសង្ខេបជាភាសាអង់គ្លេស (Fundraise proposal English Version)

២- រូបភាព កញ្ចប់សម្រាប់ឧបត្ថម្ភ

៣- ទម្រង់កិច្ចព្រមព្រៀង